00628505

លេខ/No: D427/1/19

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស. (អ.ប.ជ.៧៥)

ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: បារាំង

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ អ.ប.ជ. សាធារណៈ / Public

ស្ថានភាពនៃចំណាត់ថ្នាក់:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 29 / 11 / 2010
ម៉ោង (Time/Heure): 10 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

---

## កំណត់សម្គាល់រួមចំពោះបណ្តឹងឧទ្ធរណ៍
## ដាក់ដោយ លោក នួន ជា លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ
## ប្រឆាំងនឹងដីកាដំណោះស្រាយ

---

<u>ដាក់ដោយ</u>៖

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ឡោ ជុនធី

លោក Olivier BAHOUGNE

<u>ជំនួយការ</u>៖

កញ្ញា ឈឿន សុភាព

កញ្ញា សុជាតិ ជននីនាថ

<u>ផ្ញើជូន</u>៖

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Catherine MARCHI-UHEL

ចៅក្រម Rowan DOWNING

កំណត់សម្គាល់រួមចំពោះបណ្តឹងឧទ្ធរណ៍ដាក់ដោយ លោក នួន ជា លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ

Original FR: 00623592-00623611

កញ្ញា Andrey ROELANDT

លោក ទុយ ច័ន្ទ

**សហមេធាវីការពារក្តីជនត្រូវចោទ៖**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

លោក ផាត់ ពៅស៊ាង

លោកស្រី Diana ELLIS

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew T.CAYLEY

**មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក គីម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោក Phillipe CANONNE

លោកស្រី Elizabeth RABESANDRATANA

លោកស្រី Annie DELAHAIE

លោកស្រី Fabienne TRUSSES-NAPROUS

លោក Ferdinand DJAMMEN-NZEPA

លោកស្រី Christine MARTINEAU

លោកស្រី Laure DESFORGES

លោកស្រី Isabelle DURAND

លោកស្រី Francoise GAUTRY

លោក Barnabe NEKUIE

លោកស្រី Nicole DUMAS

លោក Daniel LOSQ

លោក នី ចាន់ឌី

លោកស្រី Lyma NGUYEN

លោក Mahdev MOHAN

លោកស្រី Marie GUIRAUD

លោក Patrick BAUDOIN

លោកស្រី ជេត វណ្ណាលី

លោក ពេជ អង្គ

លោក វ៉ែន ពៅ

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក យុង ផានិត

លោកស្រី ស៊ិន សុវ៉ន

លោកស្រី Silke STUDZINSKY

លោក Pascal AUBOIN

លោក Julien RIVET

លោក Emmanuel ALTIT

លោក Emmanuel JACOMY

# សេចក្តីផ្តើម និងបណ្តឹង

១. បានឃើញដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០១០ ("ដីកាដំណោះស្រាយ")។[1]

២. បានឃើញបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ របស់ក្រុមមេធាវីការពារក្តីរបស់ លោកស្រី អៀង ធីរិទ្ធ[2] លោក នួន ជា[3] និង លោក អៀង សារី[4] ដែលបណ្តឹង ឧទ្ធរណ៍ពីរដំបូងត្រូវបានជូនដំណឹងជាភាសាអង់គ្លេស និងខ្មែរ មួយនៅថ្ងៃទី១៩ ខែតុលា និងមួយទៀត នៅថ្ងៃទី២១ ខែតុលា រីឯបណ្តឹងឧទ្ធរណ៍ទីបី ត្រូវបានជូនដំណឹងជាភាសា អង់គ្លេស នៅថ្ងៃទី២៦ ខែតុលា និងជាភាសាខ្មែរនៅថ្ងៃទី៥ ខែវិច្ឆិកា។

៣. បានឃើញដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ ដែលបាន ជូនដំណឹងជាភាសាអង់គ្លេស បារាំង និងខ្មែរ នៅថ្ងៃជាមួយគ្នា "អនុញ្ញាតឱ្យសហព្រះរាជ អាជ្ញាដាក់ចម្លើយតបរួមមួយទៅនឹងបណ្តឹងឧទ្ធរណ៍ទាំងនោះ ដែលបានធ្វើឡើងដោយ លោក អៀង សារី លោកស្រី អៀង ធីរិទ្ធ និងលោក នួន ជា ប្រឆាំងនឹងដីកាដំណោះ ស្រាយ [...] ក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ជាភាសាអង់គ្លេស និងខ្មែរ។ ចំនួនទំព័រដែលអនុញ្ញាតសម្រាប់ចម្លើយតបរួមនេះ ស្មើនឹង ចំនួនទំព័រនៃបណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេសទាំងបី"។ អង្គបុរេជំនុំជម្រះបញ្ជាក់ថា "ភាគីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិដាក់កំណត់សម្គាល់ គាំទ្រចម្លើយនៃការចោទប្រកាន់ ចំពោះបណ្តឹងឧទ្ធរណ៍ដែលបានដាក់ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងរយៈពេលប្រាំថ្ងៃ

---

[1] *ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427។

[2] *បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/2/1។

[3] *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* (នួន ជា) ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/3/1។

[4] *បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/1/6 និង *សេចក្តីបន្ថែមភ្ជាប់ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០។

ចាប់ពីពេលដាក់ចម្លើយរបស់សហព្រះរាជអាជ្ញា។ អង្គបុរេជំនុំជម្រះជំរុញភាគីដើមបណ្តឹងរដ្ឋប្បវេណីឱ្យដាក់ចម្លើយរួម ក្នុងករណីដែលអាចធ្វើទៅបាន"។[5]

៤. បានឃើញចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ដាក់នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ និង ជូនដំណឹងនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១០ ។[6]

៥. សហមេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំអង្គបុរេជំនុំជម្រះមេត្តាៈ

- ប្រកាសនូវកំណត់សម្គាល់រួមចំពោះបណ្តឹងឧទ្ធរណ៍របស់ក្រុមសហមេធាវីរបស់ លោកស្រី អៀង ធីរិទ្ធ លោក នួន ជា និង លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលបានដាក់ក្នុងពេលវេលាដែលបានកំណត់ដោយភាគីដើមបណ្តឹងរដ្ឋប្បវេណី។

- គិតពិចារណាទៅលើកំណត់សម្គាល់ ដែលបានដាក់ឥឡូវនេះ ដើម្បីគាំទ្រដល់ចម្លើយរបស់សហព្រះរាជអាជ្ញា នៅពេលដែលអង្គបុរេជំនុំជម្រះធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។

## សេចក្តីសំអាង

៦. ដោយផ្អែកលើសិទ្ធិដែលបានផ្តល់ឱ្យ ក្នុងការធ្វើកំណត់សម្គាល់របស់ខ្លួន ភាគីដើមបណ្តឹងរដ្ឋប្បវេណីសូមដាក់កំណត់សម្គាល់រួមទាំងអស់ ចំពោះបណ្តឹងឧទ្ធរណ៍របស់ លោកស្រី អៀង ធីរិទ្ធ លោក នួន ជា និង លោក អៀង សារី ("ជនត្រូវចោទ")។[7]

---

[5] *សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំដាក់ចម្លើយតបរួមទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើសុំបន្ថែមចំនួនទំព័រកំណត់* អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/1/8។

[6] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/1/17

## I. ជនជាប់ចោទបានបកស្រាយដោយគាន់ច្រឡំ ដោយកត់សម្គាល់ថាច្បាប់អន្តរជាតិទាក់ទងទៅនឹងឧក្រិដ្ឋកម្មអន្តរជាតិ ដែលពួកគាត់ត្រូវបានចោទប្រកាន់ មិនអាចយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក ទេ

៧. គេនឹងអាចបង្ហាញបានថា ច្បាប់អន្តរជាតិនៃអនុសញ្ញានឹងអាចអនុវត្តបាន ម៉្យាងដោយមកពីច្បាប់នេះត្រូវបានអនុម័តមុនការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ហើយម៉្យាងទៀត ដោយមកពីការអនុវត្តនូវច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ នៅទីបញ្ចប់ បើសិនជាចាំបាច់ គេនឹងត្រូវរំឭកឡើងវិញថា អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ក្នុងក្របខណ្ឌនៃការកាត់ទោស *ឌុច* បានយល់ឃើញថាខ្លួនអាចសំអាងលើ "ទាក់ទងនឹងប្រភពពាក់ព័ន្ធនៃច្បាប់អន្តរជាតិដែលអនុវត្តក្នុងអំឡុងពេលនោះ អង្គជំនុំជម្រះអាចផ្អែកលើច្បាប់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់អនុសញ្ញាអន្តរជាតិ ព្រមទាំងគោលការណ៍ទូទៅនៃច្បាប់ដែលបានទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ"។[8]

### ១) ច្បាប់អនុសញ្ញាអន្តរជាតិដែលអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក

៨. វាជាការខុសឆ្គងដែលជនជាប់ចោទទាំងអស់បានថ្លែង ដោយសង្កត់ទៅលើទឡ្ហីករណ៍ដូចគ្នាថា អនុសញ្ញាក្រុងហ្សឺណែវទាំងបួន និងអនុសញ្ញាស្ដីអំពីវិធានការបង្ការ និងបង្ក្រាបឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ("អនុសញ្ញាស្ដីអំពីបទប្រល័យពូជសាសន៍") នៅក្នុងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ មិនអាចយកមកអនុវត្តនៅប្រទេសកម្ពុជាបានទេ ហើយថាជាផលវិបាក ជនជាប់ចោទទាំងនោះមិនអាចត្រូវបានចោទប្រកាន់ ដោយស្របច្បាប់ អំពីការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បានទេ។

---

[7] ពាក្យថា « ជនជាប់ចោទ » សំដៅដល់លោក នួន ជា, លោក អៀង សារី និងអ្នកស្រី អៀង ធីរិទ្ធ។ សម្រាប់តម្រូវការដល់ការកត់សម្គាល់រួមទាំងនេះ និងលើកលែងតែអញ្ញត្រកម្មដូចដែលបានបង្ហាញ ទឡ្ហីករណ៍របស់ជនជាប់ចោទទាំងបីរូប នឹងត្រូវវិភាគក្នុងពេលជាមួយគ្នា។

[8] *ឌុច*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក កថាខណ្ឌ ៣០។

៩. អនុសញ្ញាស្តីអំពីបទប្រល័យពូជសាសន៍ និងអនុសញ្ញាក្រុងហ្សឺណែវ បានចូលជាធរមានក្នុងអំឡុងពេល នៃរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រទេសកម្ពុជាបានចូលជាសមាជិកនៃអនុសញ្ញាស្តីអំពីបទប្រល័យពូជសាសន៍ក្នុងឆ្នាំ១៩៥០[9] និងឱ្យសច្ចាប័នដល់អនុសញ្ញាក្រុងហ្សឺណែវក្នុងឆ្នាំ១៩៥៨[10] ពោលគឺនៅមុនអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ។

១០. ទោះជាជនជាប់ចោទបានដឹងច្បាស់អំពីស្ថានការណ៍នេះហើយក៏ដោយ ជនជាប់ចោទគិតថា ហេតុដែលរដ្ឋាភិបាលកម្ពុជាមិនបាននិយាយអំពីអនុសញ្ញាអន្តរជាតិទាំងនោះ ក្នុងអំឡុងពេលពីឆ្នាំ១៩៧៥ ដល់១៩៧៩ នោះ បង្ហាញថារដ្ឋាភិបាលបានគិតថាមិនមានការជាប់ទាក់ទងជាមួយអនុសញ្ញាទាំងនោះទេ។ ការពិចារណាបែបនេះមិនអាចត្រូវបានអនុម័តយកដោយអង្គបុរេជំនុំជម្រះបានឡើយ ដោយមកពីហេតុផលជាច្រើន។

ម្យ៉ាង អនុសញ្ញាទាំងនោះមិនត្រូវបានគេបដិសេធចោលនោះទេ។ មិនមានឧបករណ៍បដិសេធមិនទទួលយកអនុសញ្ញាត្រូវបានគេដាក់ចេញឡើយ។ អង្គហេតុតែមួយ គឺការមិនបានធ្វើឱ្យគេដឹងឮអំពីអនុសញ្ញានោះពីមុនមក មិនគ្រប់គ្រាន់ឱ្យគេទុកអនុសញ្ញានោះជានិរាករណ៍ទេ។[11] ឧទាហរណ៍ ទាក់ទងនឹងអនុសញ្ញាក្រុងហ្សឺណែវ កម្រងអត្ថបទអត្ថា

---

[9] ប្រទេសកម្ពុជាចូលជាសមាជិកអនុសញ្ញាស្តីអំពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ នាថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៥០ និងពុំមានការរក្សាសិទ្ធិ និងការជំទាស់អ្វីឡើយ។ សូមមើលស្ថានភាពរបស់រដ្ឋជាសមាជិក ទំព័រ ០១។

[10] ប្រទេសកម្ពុជាចូលជាសមាជិកអនុសញ្ញាក្រុងហ្សឺណែវទាំង៤ នាថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៥៨ និងពុំមានការរក្សាសិទ្ធិអ្វីឡើយ។ សូមមើល *States party to the Geneva Conventions and their additional Protocols,* របាយការណ៍ឆ្នាំ២០០៩ របស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ទំព័រ០៤។

[11] អ្នកនិពន្ធ Shawបញ្ជាក់ថា ដើម្បីបញ្ចប់សន្ធិសញ្ញាមួយ៖ "សន្ធិសញ្ញាត្រូវអស់សុពលភាព ឬព្យួរ អនុលោមតាមបញ្ញត្តិជាក់លាក់ដែលមានចែងនៅក្នុងសន្ធិសញ្ញានោះ ឬផ្សេងពីនេះ នៅពេលណាមួយដែលមានការយល់ស្របពីភាគីបន្ទាប់ពីការពិគ្រោះយោបល់គ្នា"។ ផ្ទុយទៅវិញ ការអនុវត្តសន្ធិសញ្ញាមួយមិនអាចត្រូវបានបញ្ចប់ ឬព្យួរដោយសារតែឆន្ទៈឯកតោភាគីរបស់រដ្ឋជាសមាជិកមួយនោះទេ ជាពិសេសពាក់ព័ន្ធនឹងសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្ស ឬច្បាប់មនុស្សធម៌អន្តរជាតិ។ សូមមើលសៀវភៅមានចំណងជើងថា *International Law* និពន្ធដោយ M.N. SHAW បោះពុម្ពផ្សាយលើកទី៥ ដោយ Cambridge University Press ឆ្នាំ២០០៣ ទំព័រ ៨៥១។ សូមមើលផងដែរ អនុសញ្ញាក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា ចុះកាលបរិច្ឆេទឆ្នាំ១៩៦៩ មាត្រា ៤២, ៥៤ និងកថាខណ្ឌបន្តបន្ទាប់ ពាក់ព័ន្ធនឹងការរម្លាយ និងការព្យួរការអនុវត្តសន្ធិសញ្ញា។ ទោះបីជាអនុសញ្ញាបានចូលជាធរមានបន្ទាប់ពីសម័យឆ្នាំ១៩៧៥-១៩៧៩ ក៏ដោយ ក៏បទប្បញ្ញត្តិដែលអនុសញ្ញានេះមាន អាចជួយដល់ការបកស្រាយវិធានទាំងឡាយទាក់ទងនឹងការអនុវត្តសន្ធិសញ្ញាអន្តរជាតិបានផងដែរ។

ធិប្បាយអំពីអនុសញ្ញាក្រុងហ្សឺណែវ ដឹកនាំដោយលោក Jean PICTET បានបញ្ជាក់ថា "[...] អំណាចមួយដែលនាំឱ្យបដិសេធអនុសញ្ញាចោល មិនជាប់ទាក់ទងនឹងគោលការណ៍នៃអនុសញ្ញានោះទេ ដរាបណាគោលការណ៍ទាំងនោះជាវិញ្ញត្តិនៃធានដែលមិនអាចរំលោភបាន និងវិធានសាកលនៃច្បាប់ទំនៀមទម្លាប់របស់មនុស្ស"។[12] មូលហេតុមួយទៀតដែលកាន់តែប្រសើរទៅទៀតនោះ គឺនៅពេលដែលអាជ្ញាធរនីតិបញ្ញត្តិមិនបានចាត់វិធានការណាមួយ ដើម្បីបដិសេធអនុសញ្ញាទាំងនោះ។

ម៉្យាងទៀត ដោយសារអនុសញ្ញាទាំងនោះបានចូលជាធរមាន មុនអំឡុងពេលនៃសម័យពាក់ព័ន្ធ ការផ្លាស់ប្តូររដ្ឋាភិបាលជាបន្តបន្ទាប់មិនបង្កឱ្យមានផលប៉ះពាល់អ្វីទាំងអស់ទៅលើការអនុវត្តអនុសញ្ញាទាំងនោះ។ ដូចដែលអ្នកនិពន្ធឈ្មោះ Shaw បានសរសេរថា "រឿងផ្លាស់ប្តូរបន្តបន្ទាប់នៃរដ្ឋ គួរតែផ្តាច់ចេញពីបញ្ហាផ្លាស់ប្តូរបន្តបន្ទាប់នៃរដ្ឋាភិបាល ជាពិសេសក្នុងការផ្លាស់ប្តូរបដិវត្តន៍។[13]" ដូច្នេះ ការដណ្តើមយកអំណាចរបស់ពួកខ្មែរក្រហមមិនមានផលប៉ះពាល់ណាមួយ ទៅលើការថែរក្សាធរមានភាពរបស់អនុសញ្ញានោះទេ ប៉ុន្តែវាជាការផ្ទុយទៅវិញទេ ពីព្រោះរបបខ្មែរក្រហមមិនបានធ្វើសេចក្តីប្រកាសជាផ្លូវការណាមួយ ដើម្បីបដិសេធអនុសញ្ញាទាំងនោះ។

នៅទីបញ្ចប់ លោក អៀង សារី ត្រូវបានកាត់ទោស នៅឆ្នាំ១៩៧៩ អំពី ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចមានចែងក្នុងមាត្រា២ នៃក្រឹត្យ-ច្បាប់ N.០១ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៩[14] ដែលពេលនោះ លោក អៀង សារី មិនបានធ្វើការប្តឹងតវ៉ាទេ។ ការកាត់ទោសនេះបង្ហាញថា អំណាចតុលាការកម្ពុជា និង លោក អៀង សារី បានយល់ចាត់ទុកការ

---

[12] សេចក្តីអធិប្បាយរបស់ J.S.PICTET លើអនុសញ្ញាក្រុងហ្សឺណែវ អនុសញ្ញាទីមួយ ឆ្នាំ១៩៥២៖ មាត្រា ៦៣ កថាខណ្ឌទី៤ ទំព័រ ៤១៣; អនុសញ្ញាទីពីរ ឆ្នាំ១៩៦០៖ មាត្រា ៦២ កថាខណ្ឌទី៤ ទំព័រ ២៨២; អនុសញ្ញាទីបី ឆ្នាំ១៩៦០៖ មាត្រា ១៤២ កថាខណ្ឌទី១ ទំព័រ ៦៤៧; និង អនុសញ្ញាទីបួន ឆ្នាំ ១៩៥៨៖ មាត្រា ១៥៨ កថាខណ្ឌទី៤ ទំព័រ ៦២៥។

[13] សៀវភៅមានចំណងជើងថា *International Law* និពន្ធដោយ M.N. SHAW បោះពុម្ពផ្សាយលើកទី៥ ដោយ Cambridge University Press, ឆ្នាំ២០០៣ ទំព័រ ៨៦២។

[14] សាលក្រមតុលាការប្រជាជនបដិវត្តកម្ពុជា នៅភ្នំពេញ សម្រាប់កាត់ទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រព្រឹត្តដោយបនប្រល័យពូជសាសន៍ ប៉ុល ពត - អៀង សារី ខែសីហា ឆ្នាំ១៩៧៩ និងដោយឡែកទំព័រ ៣០៩ ដល់ ៣៥១។

បង្ក្រាបឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ថាជាផ្នែករួមមួយនៃប្រព័ន្ធតុលាការ ហើយអាចប្រើជាមូលដ្ឋានគតិយុត្តក្នុងការផ្តន្ទាទោសព្រហ្មទណ្ឌ។

១១. ម្យ៉ាងវិញទៀត វាជាការឆ្លើយតបមួយទៅនឹងលោក អៀង សារី ថា ការអនុវត្តគោលការណ៍ "រំលើងឬសគល់ចាស់ទាំងស្រុង" មានករណីពិសេសតែមួយគត់ទាក់ទងទៅនឹងសិទ្ធិមនុស្ស ដោយគោលការណ៍នេះចែងថា រដ្ឋទាំងឡាយដែលទើបតែបានឯករាជ្យភាពថ្មីៗ នឹងមិនក្លាយទៅជាភាគីនៃអនុសញ្ញាណាមួយទេ ដោយសារហេតុផលតែម៉្យាង គឺអនុសញ្ញានោះចូលជាធរមានមុនថ្ងៃផ្លាស់ប្តូរដំណែង[15]។ លោក អៀង សារី បានទទួលស្គាល់ខ្លួនឯង នៅក្នុងសំណេររបស់គាត់ថា មានការពិភាក្សាចង់ដឹងថាតើគោលការណ៍ "រំលើងឬសគល់ចាស់ចោលទាំងស្រុង" អាចយកមកអនុវត្តបានដែរឬទេ។ ក៏ប៉ុន្តែ ភាគីដើមបណ្តឹងរដ្ឋប្បវេណីយល់ថា ដោយយោងទៅលើមូលដ្ឋានទ្រឹស្តីអន្តរជាតិ "ការរំលើងឬសគល់ចាស់ចោលទាំងស្រុង" មិនអាចយកមកអនុវត្តបានទេ នៅពេលសន្ធិសញ្ញាទាំងនោះជាប់ទាក់ទងនឹងសិទ្ធិមនុស្ស ដោយបញ្ជាក់ថា វិញ្ញត្តិ"សិទ្ធិមនុស្ស" ត្រូវតែយល់នៅក្នុងន័យទូលំទូលាយ ព្រមទាំងរាប់បញ្ចូលទាំងសន្ធិសញ្ញាទាក់ទងទៅនឹងច្បាប់មនុស្សធម៌អន្តរជាតិ ដូចជាអនុសញ្ញាក្រុងហ្សឺណែវ ឬសន្ធិសញ្ញាបង្ក្រាបឧក្រិដ្ឋកម្មអន្តរជាតិ ដូចជាអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ជាដើម។

ម៉្យាងទៀត គេត្រូវតែបញ្ជាក់ថា អង្គហេតុផ្សេងៗបានបង្ហាញថាពួកខ្មែរក្រហមមិនបានអនុវត្តនយោបាយ "រំលើងឬសគល់ចាស់ចោលទាំងស្រុង" ទេ ដោយហេតុថា និងដូចដែលបានបញ្ជាក់ពីមុនមក ពួកខ្មែរក្រហមមិនត្រឹមតែមិនបានបដិសេធអនុសញ្ញានោះទេ ប៉ុន្តែជាងនេះទៅទៀត ពួកគេបានគិត ក្នុងឆ្នាំ១៩៧៨ ថាពួកគេមានសិទ្ធិអំពាវនាវដល់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិថែមទៀតផង ពោលគឺពួកគេស្នើសុំឲ្យមានការអនុវត្តច្បាប់អន្តរជាតិ ដូចដែលបានអនុវត្តមុនការចូលកាន់អំណាចរបស់ពួកគេ។[16]

ក្នុងន័យនេះ អ្នកនិពន្ធ Shaw អះអាងថា ៖ "វាមិនមានអ្វីដែលត្រូវសង្ស័យនោះទេ ដែលថាសន្ធិសញ្ញានានាស្តីពីសិទ្ធិមនុស្សបង្កើតបានជាប្រភេទសន្ធិសញ្ញាពិសេស [...]។ លក្ខណៈ

---

[15] *បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/1/6 កថាខណ្ឌ ១១៧។ (យើងជាអ្នកបកប្រែ)។

[16] *ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427 កថាខណ្ឌ ១៥៤។

ពិតនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានាមានការប្រែប្រួល ខុសផ្លែក តាមបែបផែនណាមួយ ពីកិច្ចព្រមព្រៀងប្រពៃណីអន្តរជាតិ។ នៅក្នុងករណីនៃលក្ខខណ្ឌចំពោះអនុសញ្ញានៃបទប្រល័យពូជសាសន៍ តុលាការអន្តរជាតិបានសង្កត់ធ្ងន់ថា "នៅក្នុងអនុសញ្ញាបែបនេះរដ្ឋទាំងឡាយដែលបានចុះកិច្ចសន្យាមិនមានផលប្រយោជន៍ណាមួយសម្រាប់ខ្លួនទេ គេគ្រាន់តែមានប្រយោជន៍រួមមួយ គឺការបំពេញគោលបំណងដ៏ឧត្តុងឧត្តមដែលជាហេតុផលពិតនៃនុសញ្ញានោះ" [...] ដោយផ្អែកលើសារៈសំខាន់នៃសិទ្ធិបែបនេះ "រដ្ឋទាំងអស់ត្រូវបានគេជឿថាមានផលប្រយោជន៍ពេញច្បាប់សម្រាប់ការពារខ្លួន។ សិទ្ធិនោះជាសិទ្ធិសម្រាប់មនុស្សទាំងអស់គ្នា (erga omnes)""[17]។ បើនិយាយម្យ៉ាងទៀតវិញ សារៈសំខាន់ និងហេតុផលពិតនៃសន្ធិសញ្ញាទាំងនោះ ទៅហួសពីបញ្ហានៃការបន្តវេនរបស់រដ្ឋទាក់ទិននឹងសន្ធិសញ្ញាជាទូទៅ។ អ្នកនិពន្ធបន្តទៀតថា[18] ដោយស្រង់ឧទាហរណ៍អំពីស្ថានការណ៍យូហ្គោស្លាវី ក្នុងរឿងអនុវត្តអនុសញ្ញាលើបទប្រល័យពូជសាសន៍ (បុស្សនី-ហឺហ្សេហ្គូវីន ប្រឆាំងនឹងយូហ្គោស្លាវី) នៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ និងដោយលើកឡើងវិញនូវមតិដាច់ដោយឡែករបស់ចៅក្រម Weeramantry ដែលបានយល់ថា នៅក្នុងកថាខណ្ឌដែលមានចំណងជើងថា "អញ្ញត្រកម្មពិសេសក្នុងគោលការណ៍នៃការរំលើងឬសគល់ចាស់ចោលទាំងស្រុង" ថា "សន្ធិសញ្ញាទាក់ទងទៅនឹងសិទ្ធិមនុស្ស និងសន្ធិសញ្ញានានាដែលមានលក្ខណៈមនុស្សធម៌ មិនធ្វើឲ្យបាត់បង់អធិបតេយ្យភាព ឬស្វ័យភាពសម្រាប់រដ្ឋថ្មីទាល់តែសោះ ប៉ុន្តែសន្ធិសញ្ញាទាំងនោះគ្រាន់តែអនុលោមទៅតាមគោលការណ៍ទូទៅនៃការការពារ ដែលប្រសូត្រចេញមកពីសេចក្តីថ្លៃថ្នូរដែលមានជាប់មកជាមួយមនុស្សគ្រប់រូប ហើយសេចក្តីថ្លៃថ្នូរនោះជាមូលដ្ឋានគ្រឹះនៃធម្មនុញ្ញអង្គការសហប្រជាជាតិ [...]។ ជាពិសេសទៅទៀត ហេតុផលទាំងអស់នេះមានតម្លៃយ៉ាងខ្លាំង សម្រាប់សន្ធិសញ្ញានានា ដូចជាអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ [...] ហើយមិនធ្វើឱ្យមានមន្ទិលសង្ស័យចំពោះការបន្តវេនជាស្វ័យប្រវត្តិរបស់សន្ធិសញ្ញាបែបនេះ"[19] ។

---

[17] សៀវភៅមានចំណងជើងថា *International Law* និពន្ធដោយ M.N. SHAW បោះពុម្ពផ្សាយលើកទី៥ ដោយ Cambridge University Press, 2003 ទំព័រ ៨៨៦។

[18] សៀវភៅមានចំណងជើងថា *International Law* និពន្ធដោយ M.N. SHAW បោះពុម្ពផ្សាយលើកទី៥ ដោយ Cambridge University Press, 2003 ទំព័រ ៨៨៨។

[19] *សំណុំរឿងពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញាស្តីអំពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (ប្រទេស Bosnie-Herzégovine តទល់នឹងប្រទេស Yougoslavie)* « មតិយោបល់ដាច់ដោយឡែករបស់លោក

១២. ទាក់ទិននឹងអនុសញ្ញាក្រុងហ្សឺណែវ លោកសាស្ត្រាចារ្យ Cassese បានអះអាងយ៉ាងច្បាស់ថា ៖ "នៅក្នុងអត្ថបទទាំងនេះ [ដូចជាអនុសញ្ញាក្រុងហ្សឺណែវ គេមិនគ្រាន់តែឃើញ [...] វិញ្ញត្តិនៃកាតព្វកិច្ចក្នុងការពិន័យ បង្ក្រាបឧក្រិដ្ឋកម្មទាំងនោះប៉ុណ្ណោះទេ។ អ្វីដែលមានសារៈសំខាន់បំផុតនោះ និយាយឱ្យចំ គឺថាការបង្ក្រាបមិនមែនជាសមត្ថកិច្ចរបស់រដ្ឋទាំងឡាយ [...] មិនមែនជាសេចក្ដីអនុញ្ញាតដែលច្បាប់អន្តរជាតិផ្ដល់ឱ្យទៅរដ្ឋទាំងឡាយនោះទៀតទេ]។ ការបង្ក្រាបមិនបានត្រូវទុកឱ្យរដ្ឋទាំងឡាយធ្វើស្រេចតែតាមអំពើចិត្តទេ ប៉ុន្តែរដ្ឋទាំងឡាយនោះ *ត្រូវតែធ្វើជាចាំបាច់*។ ត្រង់ចំណុចនេះ គេត្រូវតែកត់សម្គាល់ថា ដោយអនុលោមទៅតាមតុលាការយុត្តិធម៌អន្តរជាតិ នៅក្នុងយោបល់ពិគ្រោះអំពី*ធម្មានុរូបភាពនៃការគំរាមកំហែង ឬការប្រើអាវុធនុយក្លេអ៊ែរ* (១៩៩៦ កថាខណ្ឌ៧៩-៨២) ថា វិធានជាមូលដ្ឋាន នៃអនុសញ្ញាក្រុងហ្សឺណែវ បានក្លាយទៅជាផ្នែកទាំងមូលនៃច្បាប់ទំនៀមទម្លាប់។ ក្នុងចំណោមច្បាប់ទាំងនោះ គេក៏ត្រូវយល់ដែរនូវអ្វីដែលស្ដីអំពីការបង្ក្រាបព្រហ្មទណ្ឌនៃបទល្មើសធ្ងន់ធ្ងរ"[20]។

**២) វាជាកំហុសខុសឆ្គងដែលជនជាប់ចោទសន្និដ្ឋានថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងជាពិសេស វិធានអាជ្ញាបញ្ញា (jus cogens) មិនអាចយកមកអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក**

---

Weeramantry », តុលាការយុត្តិធម៌អន្តរជាតិ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩៦ ទំព័រ៦៤០ ដល់ ៦៥៥ និងដោយឡែកទំព័រ ៦៤៥។ (យើងជាអ្នកគូសពីក្រោម)។

[20] « L'incidence du droit international sur le droit interne », សរសេរដោយ A. CASSESE ក្នុងសៀវភៅមានចំណងជើងថា *Juridictions nationales et crimes internationaux* បោះពុម្ពផ្សាយដោយ Presses Universitaires de France ទំព័រ ៥៥៧។ សូមមើលផងដែរ សៀវភៅមានចំណងជើងថា *Direct Application of International Criminal Law in National Courts* និពន្ធដោយ W.N.FERDINANDUSSE, គ្រឹះស្ថានបោះពុម្ពផ្សាយ T.M.C. Asser Press ឆ្នាំ២០០៦ ទំព័រ ២៦០។ L'auteur constate que «The provisions on grave breaches [of the Geneva Convention] clearly define the acts in question, and can also be said to criminalize them. [...] In this regard, it is significant that the States Parties are not required to criminalize the grave breaches [...] but merely to provide effective penal sanctions, which suggests that the acts are already criminalized under international law».

១៣. ជនជាប់ចោទនីមួយៗបានអះអាងថា ៖ ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនអាចយកមកអនុវត្តដោយផ្ទាល់ក្នុងច្បាប់កម្ពុជាទេ ហើយជាផលវិបាក នឹងមិនអាចប្រើជាមូលដ្ឋានក្នុងការចោទប្រកាន់ព្រហ្មទណ្ឌទេ ជាពិសេស នៅពេលដែលអង្គហេតុនានាកើតឡើង ការបង្ក្រាបទាំងនោះមិនទាន់ជាបទដ្ឋាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឡើយ។

១៤. ជនជាប់ចោទទាំងអស់នឹងត្រូវរំឭកឡើងវិញថា ឧក្រិដ្ឋកម្មទាំងពួងដែលបានកំណត់ (បទប្រល័យពូជសាសន៍ ការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ត្រូវបានរាប់ចូលក្នុងកម្រងច្បាប់ប្រពៃណីអន្តរជាតិ ហើយជាភាគទាំងមូលនៃកម្រងបទដ្ឋានដែលមានកំណត់នៃ ***វិធានអាជ្ញាបញ្ញា*** *(jus cogens)*។[21]

១៥. មកដល់ចំណុចនេះ លោក នួន ជា មិនសូវជឿជាក់លើទឡ្ហីករណ៍របស់ខ្លួនគាត់ផ្ទាល់ទេ ទាក់ទងទៅនឹងប្រធានបទនៃលក្ខន្តិកៈស្ដីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយការស្ទាក់ស្ទើររបស់គាត់បានលេចចេញនៅក្នុងអត្ថបទសរសេររបស់គាត់ផ្ទាល់។[22] ផ្ទុយទៅវិញ នេះមិនមែនជាករណីនៃទ្រឹស្ដី និងយុត្តិធម៌អន្តរជាតិ ដែលបានស្រុះស្រួលគ្នាដើម្បីពិចារណាលើការហាមឃាត់មិនឱ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានការជាប់ទាក់ទងទៅនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ អង្គជំនុំជម្រះសាលាដំបូង ដោយសំអាងលើយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ និងការទទួលស្គាល់ក្នុងលក្ខន្តិកៈនានា នៃបណ្ដាតុលាការអន្តរជាតិបានសន្និដ្ឋានថា ៖ "ចាប់តាំងពីលក្ខន្តិកៈ Nuremberg មក ចរិតលក្ខណៈជាទំនៀមទម្លាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ [...] មិនបានត្រូវគេជំទាស់មែនទែនទេ" ហើយម្យ៉ាងទៀត "តុលាការអន្តរជាតិទាំងនោះបានអះអាង បញ្ជាក់ឡើងវិញ នូវលក្ខណៈជាទំនៀមទម្លាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងច្បាប់អន្តរជាតិ"។ នៅទីបញ្ចប់ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា "និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចមានចែងក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក ស្របគ្នាទៅនឹងនិយមន័យដែលមានក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងពេលពីឆ្នាំ១៩៧៥ ដល់ ១៩៧៩"។ ដូច្នេះគេអាចសន្និដ្ឋានថា

[21] សូមមើលជាពិសេសសៀវភៅមានចំណងជើងថា *Introduction to International Criminal Law* និពន្ធដោយ M.C. BASSIOUNI គ្រឹះស្ថានបោះពុម្ពផ្សាយ Transnational Publishers ទំព័រ ៧០១។

[22] *បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/3/1, កថាខណ្ឌ ១១។

"[...] គេអាចព្យាករបានថា ជនជាប់ចោទអាចឃើញការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនមានការទាក់ទងទៅនឹងបទល្មើស ដែលខ្លួនត្រូវតែទទួលស្គាល់ ដោយអនុវត្តតាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក។ វិធាននៃច្បាប់នោះដែលអនុញ្ញាតឱ្យទទួលយកការទទួលខុសត្រូវបែបនេះ មានលក្ខណៈគ្រប់គ្រាន់ ដែលជនជាប់ចោទអាចទទួលយកបាន ដោយហេតុថានៅសម័យនោះ វិធានទាំងនោះត្រូវបានទទួលស្គាល់ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ"។[23]

១៦. ជាមួយគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានយល់ឃើញថា ខ្លួនអាចផ្អែកលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ដើម្បីធានាឲ្យមានការគោរពនូវគោលការណ៍នីត្យានុកូលភាព អង្គបុរេជំនុំជម្រះបានយោងទៅលើសេចក្ដីសម្រេច របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលសេចក្ដីសម្រេចនេះយល់ឃើញថា "ទាក់ទងនឹងភាពអាចដឹងជាមុនបាន អាកប្បកិរិយាដែលចោទជាបញ្ហាគឺជាអាកប្បកិរិយា ផ្ទាល់របស់ជនជាប់ចោទ។ ជនជាប់ចោទត្រូវតែអាចដឹងថា តើអាកប្បកិរិយារបស់ខ្លួនមានលក្ខណៈឧក្រិដ្ឋ ដូចក្នុងន័យដែលគេយល់ឃើញជាទូទៅដែរឬទេ ដោយមិនចាំបាច់យោងទៅលើបទប្បញ្ញត្តិជាពិសេសណាមួយនោះទេ។ ចំពោះភាពដែលជនជាប់ចោទអាចទទួលយកបាន អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើគោលការណ៍គតិយុត្ត ដែលផ្អែកលើវិធានទំនៀមទម្លាប់"។

ហើយអង្គបុរេជំនុំជម្រះសាលាដំបូងពិតជាបានសំអាងលើវិធានទំនៀមទម្លាប់ ជាពិសេសទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[24] ដើម្បីធ្វើការវិនិច្ឆ័យ។

១៧. ផ្ទុយទៅនឹងអ្វីដែល លោក អៀង សារី បានប្រកាស លក្ខន្តិកៈនៃ *វិធានអាជ្ញាបញ្ញា* មានឥទ្ធិពលទៅលើច្បាប់ជាតិកម្ពុជា ដោយសារលក្ខណៈដោយឡែកនៃបទដ្ឋានដ៏ពិសេស ទាំងនេះអាចអនុវត្តបាន *សម្រាប់ជនគ្រប់រូប (erga omnes)* ។ នេះមិនមែនគ្រាន់តែជា "គោល

[23] *ដូច*សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក កថាខណ្ឌ ២៨៤ ដល់ ២៨៦។

[24] *ដូច* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក កថាខណ្ឌ ២៨០៖ « ទម្រង់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចមានចែងនៅក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក ដូចគ្នានឹងទម្រង់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩"។

ជំហរបុព្វសិទ្ធិ”[25] ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនាំឱ្យមានកាតព្វកិច្ច ដែលទៅហួសពីសញ្ញាណនៃអធិបតេយ្យភាពនៃរដ្ឋទៀតផង។ ទាក់ទងនឹងចំនុចនេះ អ្នកនិពន្ធ De Than និង Shorts បានបញ្ជាក់ថា “ជាផលវិបាកនៃលក្ខន្តិកៈនៃ *វិធានអាជ្ញាបញ្ញា* [បទដ្ឋាន] គឺជាកាតព្វកិច្ច *សម្រាប់ជនគ្រប់រូប* ហើយដូច្នេះ [វា]បង្កើតជាករណីយកិច្ច ដែលគេមិនអាចរំលោភបាន”[26]។

**៣) ជនជាប់ចោទបានប្រព្រឹត្តកំហុសខុសឆ្គងក្នុងការបកស្រាយ ដោយធ្វើការសន្និដ្ឋានថា អញ្ញត្រកម្មនៃមាត្រា ១៥ (២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនអាចយកមកអនុវត្តបាន នៅចំពោះមុខ អ.វ.ត.ក**

១៨. ជាច្រើនលើកច្រើនសា ជនជាប់ចោទ ជាពិសេស លោក នួន ជា[27] និង លោក អៀង សារី[28]បានបដិសេធចោលនូវវិធីទាញរកហេតុផលរបស់សហចៅក្រមស៊ើបអង្កេត ដោយតាមរយៈវិធីនេះ សហចៅក្រមអាចមានមូលដ្ឋាន និងសំអាងហេតុលើសមត្ថកិច្ចនៃ អ.វ.ត.ក ដោយសំអាងលើអញ្ញត្រកម្មដែលមានចែងក្នុងមាត្រា ១៥ (២) នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយលើកអំណះអំណាងជាអាទិ៍ថា គោលការណ៍នីត្យានុកូលភាព ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ត្រូវបានតាក់តែងយ៉ាងហ្មត់ចត់ជាងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយទៅទៀត។ សហចៅក្រមបានធ្វើការសន្និដ្ឋានថា គោលការណ៍នីត្យានុកូលភាពជាតិមានប្រៀបលើគោលការណ៍នៅក្នុងន័យអន្តរជាតិ។

---

[25] *បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/1/6 កថាខណ្ឌ ១២៦។

[26] សៀវភៅមានចំណងជើងថា *International Criminal Law and Human Rights* និពន្ធដោយ C. de THAN et E. SHORTS, Thomson, Sweet & Maxwell ឆ្នាំ២០០៣ ទំព័រ១០។ (យើងជាអ្នកបកប្រែ)។

[27] *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/3/1 កថាខណ្ឌ ៣៦៖ “Criminalization of prior conduct in a subsequent legal order fails to satisfy the forseeability requirement of national *nullum crimen*. While the exception to the international principle of legality (ICCPR, Article 15 (2)) would arguably apply were the ECCC an international tribunal like the ICTY or SCSL, it strains reason to suggest that Nuon Chea could have forseen internationally-based criminality in a Cambodian court”.

[28] *បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី២៥ តុលា ឆ្នាំ២០១០ ឯកសារ D427/1/6 កថាខណ្ឌ ១០៧ ដល់ ១០៩។

១៩. ក៏ប៉ុន្តែ មាត្រានៃកតិកាសញ្ញាអន្តរជាតិ ដែលលើកឡើងពីគោលការណ៍នីត្យានុកូលភាព ចែង នៅក្នុងកថាខណ្ឌទី២ ថា៖ "បើតាមគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ ដោយប្រជាជាតិទាំងអស់ មិនមានបទប្បញ្ញត្តិណាមួយ នៅក្នុងមាត្រានេះ ដែលចែងផ្ទុយ ទៅនឹងការវិនិច្ឆ័យ ឬការផ្តន្ទាទោសដល់ជនគ្រប់រូប ដោយមូលហេតុអំពើសកម្ម ឬអកម្ម ដែលត្រូវបានចាត់ទុកថាជាអំពើឧក្រិដ្ឋ នៅខណៈដែលអំពើទាំងនេះត្រូវបានប្រព្រឹត្ត"[29]។ ឬអាចនិយាយម្យ៉ាងទៀតថា "អញ្ញត្រកម្មនេះអនុញ្ញាតឱ្យមានការវិនិច្ឆ័យ និងការផ្តន្ទាទោសដល់ជនគ្រប់រូប ដែលត្រូវបានចោទប្រកាន់ថាបានរំលោភគោលការណ៍ជាទូទៅនៃច្បាប់អន្តរជាតិ ទោះបីជាមានលក្ខន្តិកៈព្រហ្មទណ្ឌនៃអំពើអស់ទាំងនេះ នៅក្នុងច្បាប់ជាតិនៃរដ្ឋដែលពាក់ព័ន្ធក៏ដោយ។ កថាខណ្ឌនេះនិយាយសំដៅយ៉ាងពិតប្រាកដទៅលើជនទាំងឡាយណា ដែលបានរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ រួមមានឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[30]។ សហចៅក្រមស៊ើបអង្កេតគ្រាន់តែគោរពតាមយុត្តិសាស្ត្រជាអចិន្ត្រៃយ៍ របស់អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ប៉ុណ្ណោះ។

២០. អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួនថា " ដើម្បីអាចឱ្យបទឧក្រិដ្ឋមួយត្រូវបានចាត់ចូលជាបទល្មើសនៅក្នុងសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក ខណៈដែលបទឧក្រិដ្ឋនោះមិនត្រូវបានចាត់ជាបទល្មើសនៅក្នុងបញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាតិ <u>បទឧក្រិដ្ឋនោះត្រូវតែមានចែងដោយចំ ឬមិនចំ នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ហើយបទឧក្រិដ្ឋនោះត្រូវតែជាបទល្មើសនៅក្រោមបញ្ញត្តិនៃច្បាប់អន្តរជាតិដែល អនុវត្តនៅក្នុងប្រទេសកម្ពុជា នៅក្នុងអំឡុងពេលនៃអង្គហេតុ</u>"[31]។

២១. អាស្រ័យហេតុនេះ នៅក្នុងសាលក្រមប្រឆាំងនឹង **ឌុច** អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខ្លួនមានទំនួលខុសត្រូវក្នុងការ"កំណត់ថាតើឧក្រិដ្ឋកម្ម និងទម្រង់ពិសេសៗនៃទំនួលខុសត្រូវ ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលត្រូវបានកែប្រែ

---

[29] កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (« PIDCP ») ឆ្នាំ១៩៦៦។

[30] *កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ,* S. JOSEPH, J. SCHULTZ, M. CASTAN, បោះពុម្ពផ្សាយដោយ Oxford University Press ទំព័រ៤៦៩ កថាខណ្ឌ ១៥.១១។ (យើងជាអ្នកបកប្រែ)។

[31] *ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត* កថាខណ្ឌ ១៣០២។

ត្រូវបានទទួលស្គាល់ដោយច្បាប់ជាតិកម្ពុជា ឬ ដោយច្បាប់អន្តរជាតិ រវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដែរឬទេ"[32]។ ការប្រើប្រាស់សន្ធានស័ព្ទ "ឬ" ជាជាង "និង" បញ្ជាក់ឱ្យឃើញថា គ្រាន់តែអត្ថិភាព នៃឧក្រិដ្ឋកម្មមួយ ក្នុងច្បាប់អន្តរជាតិ ដូចដែលបានចោទប្រកាន់ដល់ជនជាប់ចោទ គឺមានលក្ខណៈគ្រប់គ្រាន់អាចឱ្យធ្វើការវិនិច្ឆ័យបានទៅហើយ។

## II. ស្តីពីការរំលោភគោលការណ៍នីត្យានុកូលភាពដែលបានលើកឡើង

២២. ជនជាប់ចោទអះអាងថា គោលការណ៍នីត្យានុកូលភាពត្រូវបានរំលោភ ដោយមូលហេតុដូចតទៅនេះ៖

ក. មិនមានច្បាប់ជាតិដែលមានចែងពីការអនុវត្តបាននៃឧក្រិដ្ឋកម្ម អន្តរជាតិដែលលើកឡើងនោះទេ។
ខ. ទាំងអនុសញ្ញាទីក្រុងហ្សឺណែវ និងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ សុទ្ធតែមិនអាចអនុវត្តបានដោយផ្ទាល់ នៅក្នុងច្បាប់ជាតិកម្ពុជា។
គ. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនអាចបង្កើតច្បាប់ ហើយថែមទាំង មិនអាចអនុវត្តបានតាមបែបប្រតិសកម្មទៀតផង។

២៣. មានអំណះអំណាងផ្ទុយចំនួនពីរដែលអាចត្រូវបានលើកមកបង្ហាញ៖

ទីមួយ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់រួចមកហើយថា "ការដែល អ.វ.ត.ក ត្រូវបានបង្កើត និងផ្តល់យុត្តាធិការឱ្យដោះស្រាយឧក្រិដ្ឋកម្មដែលបានបានប្រព្រឹត្តមុនពេលការបង្កើតអវតក ក៏នេះមិនបានរំលោភបំពានលើគោលការណ៍នីត្យានុកូលភាពនោះដែរ"[33]។ ទីពីរ គេត្រូវរាប់បញ្ចូលនូវមុខងារបំលែងទៅតាមច្បាប់ជាតិ នូវឧក្រិដ្ឋកម្មអន្តរជាតិ នៃច្បាប់ឆ្នាំ២០០១ បន្ទាប់មកត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ឆ្នាំ២០០៤ ដែលកំណត់ពី

---

[32] *ដូច*សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក កថាខណ្ឌ ២៨។ (យើងជាអ្នកគូសពីក្រោម)។

[33] *ដូច*សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក កថាខណ្ឌ ៣៥។

សមត្ថកិច្ចរបស់ អ.វ.ត.ក[34]។ ជាក់ស្តែង “រដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ យល់ឃើញយ៉ាងច្បាស់ថា ខ្លួនមានសិទ្ធិពិចារណាថ្លឹងថ្លែងអំពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ដែលត្រូវបានកំណត់ ខណៈដែលមានអង្គហេតុ ដោយអនុលោមទៅតាមច្បាប់នីតិវិធីដែលមាននៅពេលក្រោយ ដូចមានចែងនៅក្នុងមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ”[35]។ ដូច្នេះ គេត្រូវគិតបញ្ចូលផងដែរថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនបង្កើតច្បាប់នោះទេ ពោលគឺគ្រាន់តែបំលែងច្បាប់នៃអនុសញ្ញា និងទំនៀមទម្លាប់អន្តរជាតិ ដែលមានស្រាប់ នៅសម័យកម្ពុជាប្រជាធិបតេយ្យ នៅក្នុងច្បាប់ជាតិកម្ពុជា។

២៤. យុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ និងទ្រឹស្តីបានយកចិត្តទុកដាក់ជាពិសេសទៅលើ “បញ្ហានេះ ដើម្បីដឹងថា តើផលប្រតិសកម្មនៃវិធានសមត្ថកិច្ច ទាក់ទងនឹងឧក្រិដ្ឋកម្មអន្តរជាតិ អាចរំលោភសិទ្ធិមនុស្ស ជាពិសេសគោលការណ៍ *“បើគ្មានច្បាប់ចែងជាមុនទេ គ្មានឧក្រិដ្ឋកម្ម គ្មានការដាក់ទោសនោះទេ”* ដែលមានចែងនៅក្នុងមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ [...] ជាមួយគ្នានេះដែរ នៅក្នុងរឿងក្តី Delalic និងរឿងក្តីផ្សេងៗទៀត អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី បានវិនិច្ឆ័យថាលក្ខន្តិកៈរបស់ខ្លួន “មិនបង្កើតច្បាប់ វត្ថុវិស័យទេ ក៏ប៉ុន្តែបង្កើតស្ថាប័ន និងក្របខណ្ឌមួយ ដើម្បីអនុវត្តច្បាប់មនុស្សធម៌ អន្តរជាតិ”។ ដូច្នេះ ប្រតិសកម្មភាពនៃវិធានសមត្ថកិច្ចជាតិមិនបានរំលោភមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិនោះទេ [...]។ ជាដំបូង ដោយសារវិធានសមត្ថកិច្ច មិនមានឥទ្ធិពលទៅលើគុណសម្បត្តិផ្លូវចិត្តនៃអាកប្បកិរិយាមនុស្សនោះទេ គោលការណ៍ *គ្មានឧក្រិដ្ឋកម្ម* មិនអាចអនុវត្តបានទេ នៅក្នុងករណីនេះ។ បន្ទាប់មក ដោយសារកថាខណ្ឌទី២ [នៃមាត្រានេះ] ផ្តល់សេរីភាពឲ្យដល់រាល់ភាគីចុះកិច្ចសន្យា ក្នុងការផ្តល់ផលប្រតិសកម្មដល់វិធានសមត្ថកិច្ច ទាក់ទងនឹង

---

[34] *ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ* អនុម័តខែមករា ឆ្នាំ២០០១។ ច្បាប់នេះត្រូវបានធ្វើវិសោធនកម្ម និងប្រកាសឲ្យប្រើថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

[35] សូមមើលជាពិសេស អត្ថបទរបស់ D. BOYLE មានចំណងជើងថា « តុលាការកូនកាត់ទទួលបន្ទុកកាត់ទោសខ្មែរក្រហម » ក្នុងផ្នែកពាក់ព័ន្ធនឹង *Droits Fondamentaux*, លេខ១ ខែកក្កដា - ធ្នូ ២០០១ ទំព័រ ២១៣ ដល់ ២២៧ និងដោយឡែកទំព័រ ២២៤ និង ២២៥។

រាល់អាកប្បកិរិយាដែលបង្កើតជាឧក្រិដ្ឋកម្មរួចហើយ តាមច្បាប់អន្តរជាតិ នៅចុងសង្គ្រាមលោកលើកទីពីរ"[36]។

២៥. ជាមួយគ្នានេះដែរ ដោយបានឃើញការលើកឡើងពីខាងដើម យើងឃើញថាភាពអាចអនុវត្តបាននៃឧក្រិដ្ឋកម្មអន្តរជាតិ របស់អង្គជំនុំជម្រះ អនុលោមតាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដោយយោងលើអង្គហេតុ មិនប៉ះពាល់ដល់គោលការណ៍នីត្យានុកូលភាព ដោយហេតុថាច្បាប់នេះមិនបង្កើតច្បាប់វត្ថុវិស័យ ជាលក្ខណៈប្រតិសកម្ម គឺវាគ្រាន់តែបំលែងច្បាប់នេះតែប៉ុណ្ណោះ។ ច្បាប់បានមានរួចទៅហើយ។

*** ជនជាប់ចោទប្រព្រឹត្តកំហុសខុសឆ្គងផ្នែកច្បាប់ ដោយមិនបានគិតបញ្ចូលនូវយុត្តិសាស្ត្រនៃ អ.វ.ត.ក**

២៦. ទោះបីជាក្រុមការពារក្តីដកស្រង់សាលក្រមនៃអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក នៅក្នុងសំណុំរឿង ០០១ ក៏ដោយ ក៏ក្រុមការពារក្តីខកខានមិនបានគិតបញ្ចូលនូវវិសាលភាពនៃសេចក្តីសម្រេចនេះ និងនៃចម្លើយទាំងឡាយដែលសហចៅក្រមបានផ្តល់ឲ្យ ដោយឆ្លើយតបទៅនឹងសំនួរទាក់ទងនឹងសមត្ថកិច្ចរបស់អង្គជំនុំជម្រះ។ ជាក់ស្តែង រាល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះបានបង្កើតជាយុត្តិសាស្ត្រមួយ នៅក្នុងផ្នែកច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។

២៧. អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ទាំងស្រុងនូវភាពអាចអនុវត្តបាន នៅក្នុងក្របខណ្ឌនៃ អ.វ.ត.ក នូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយមានបញ្ជាក់អះអាងពីអត្ថិភាពនៃឧក្រិដ្ឋកម្មទាំងនេះ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅសម័យកម្ពុជាប្រជាធិបតេយ្យ និងពីការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលបទប្បញ្ញត្តិបានប្រមូលគោលការណ៍សារវន្តនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដាក់ជាក្រុមតែមួយ។

២៨. សេចក្តីសន្និដ្ឋានដែលអនុម័តដោយអង្គជំនុំជម្រះសាលាដំបូងក៏អាចអនុវត្តបានចំពោះអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ បើធៀបជាមួយនឹងអនុសញ្ញាទីក្រុងហ្សឺណែវ។

---

[36] អត្ថបទ « តួនាទីលក្ខណៈវិនិច្ឆ័យបែបបុរាណ នៃយុត្តាធិការក្នុងការកាត់សេចក្តីបទឧក្រិដ្ឋអន្តរជាតិ» សរសេរដោយ B. SWART ក្នុងសៀវភៅមានចំណងជើងថា *Juridictions nationales et crimes internationaux* បោះពុម្ពផ្សាយដោយ Presses Universitaires de France ទំព័រ ៥៨៥ ដល់ ៥៨៦។

## III. ជនជាប់ចោទប្រព្រឹត្តកំហុសខុសឆ្គងក្នុងការវាយតម្លៃអង្គហេតុ ដោយចាត់ទុកថា ខ្លួនមិនបានដឹងពីឧក្រិដ្ឋកម្មអន្តរជាតិ ដែលបានចោទប្រកាន់ចំពោះខ្លួននោះទេ

### ១) ជនជាប់ចោទបានដឹងពីឧក្រិដ្ឋកម្មអន្តរជាតិ ដែលបានចោទប្រកាន់ចំពោះខ្លួន ដោយសារលក្ខណៈព្រៃផ្សៃជាពិសេសនៃឧក្រិដ្ឋកម្មទាំងនេះ

២៩. ស្របតាមយុត្តិសាស្ត្រ នៅក្នុងវិស័យនេះ សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ថា "លក្ខណៈព្រៃផ្សៃជាពិសេសនៃអំពើមួយ [អាច] គិតបញ្ចូល"[37]។ នៅចំនុចនេះ សហចៅក្រមស៊ើបអង្កេតគ្រាន់តែធ្វើសាឡើងវិញនូវធាតុផ្សំមួយដែលយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិបានប្រកាសរួចទៅហើយនោះ។ ជាមួយគ្នានេះដែរ តុលាការឧក្រិដ្ឋអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក[38] បានសន្និដ្ឋានថា " [...] តុលាការឧក្រិដ្ឋកម្មសង្គ្រាម ជាញឹកញាប់តែងតែបង្ហាញពីលក្ខណៈអាក្រក់គួរឱ្យស្អប់ នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ដើម្បីធ្វើការសន្និដ្ឋានថា ចារីនៃឧក្រិដ្ឋកម្មនេះមិនអាចមិនដឹងថា ខ្លួនកំពុងតែប្រព្រឹត្តនូវឧក្រិដ្ឋកម្មនោះទេ។ [...] ទោះបីជាលក្ខណៈអសីលធម៌ ឬសាហាវព្រៃផ្សៃនៃអំពើមួយមិនមែនជាធាតុផ្សំមួយគ្រប់គ្រាន់អាចធានាឱ្យមានការចោទប្រកាន់ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយ ក៏លក្ខណៈអសីលធម៌ ឬសាហាវព្រៃផ្សៃនេះអាចនាំឱ្យមានផលវិបាកដែរ ក្នុងន័យថាវាអាចបណ្តាលឱ្យមានការបដិសេធទឡ្ហីករណ៍របស់ជនជាប់ចោទ ដែលអះអាងថាគាត់មិនបានដឹងអំពីលក្ខណៈឧក្រិដ្ឋនៃអំពើទាំងឡាយរបស់ខ្លួន"។ លក្ខណៈ "អាក្រក់គួរឱ្យស្អប់" នៃអំពើមួយត្រូវបានតុលាការអន្តរជាតិក្រុង Nuremberg[39] គិតបញ្ចូលរួចទៅហើយ នៅក្នុងការវាយតម្លៃប្រភេទឧក្រិដ្ឋកម្ម។

---

[37] *ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត* កថាខណ្ឌ ១៣០២។

[38] *ឌុច* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក កថាខណ្ឌ ៣២។

[39] រឿងក្តី *Ojdanic* សាលដីកាលើអញ្ញត្រកម្មនៃអសមត្ថកិច្ច លើកឡើងដោយ Dragoljub Ojdanic - សហឧក្រិដ្ឋកម្មរួម តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៤២។

៣០. អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានទទួលស្គាល់ថា "លក្ខណៈសាហាវព្រៃផ្សៃនៃអំពើទាំងឡាយដែលបានចោទប្រកាន់ដល់ជនជាប់ចោទ [អនុលោមតាមមាត្រា៥ និង ៦ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក] អាចនាំឱ្យមានការបដិសេធនូវរាល់ទឡ្ហីករណ៍របស់ជនជាប់ចោទ ដោយអះអាងថាខ្លួនមិនបានដឹងថាអំពើអស់ទាំងនេះមានលក្ខណៈឧក្រិដ្ឋនោះទេ"[40]។ ការពិចារណានេះអនុវត្តពិសេសជាងនេះទៅទៀតចំពោះជនជាប់ចោទ លោក នួន ជា លោក អៀង សារី និង លោកស្រី អៀង ធីរិទ្ធ ដែលអ្នកទាំងអស់នេះម្នាក់ៗសុទ្ធតែបានកាន់តួនាទីខ្ពស់ៗ នៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ ដូចនឹងរៀបរាប់លម្អិតនៅខាងក្រោមនេះ។

៣១. ក្នុងករណីនេះ ដោយឃើញនូវវិសាលភាពនៃឧក្រិដ្ឋកម្ម ភាពព្រៃផ្សៃរបស់វា ក្របខណ្ឌភូមិសាស្ត្រ និងពេលវេលា (បីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ) ឬជាងនេះទៅទៀត ចំនួនជនរងគ្រោះ វាជាការមួយដែលខុស ដែលចាត់ទុកថាអំពើទាំងឡាយដែលចោទប្រកាន់ដល់ជនចាប់ចោទ មិនទាន់ឈានដល់កម្រិតដែលមាន "លក្ខណៈអាក្រក់គួរឱ្យស្អប់" នោះ។

៣២. លើសពីនេះទៅទៀត វាជាការភ័ន្តច្រឡំក្នុងការសន្និដ្ឋានថាជនជាប់ចោទមិនបានដឹងឮអំពីភាពសាហាវឃោរឃៅដែលបានប្រព្រឹត្តទៅលើប្រជាជន ហើយដែលការធ្វើបាបនេះមិនប្រកាន់ថាជាប្រជាជនចាស់ឬថ្មីនោះទេ។ ដូចចរន្តអគ្គិសនីឆក់ ភាពភ័យរន្ធត់ដែលត្រូវបានបង្កឡើង និងត្រូវបានជំរុញ ដោយការបង្ខិតបង្ខំ និងដោយអំពើហិង្សាដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ បានរាលដាល គ្របដណ្ដប់លើទូទាំងប្រទេស ហើយគ្មាននរណាម្នាក់ចៀសផុតឡើយ ទាំងជនរងគ្រោះ ទាំងអ្នកប្រព្រឹត្តឧក្រិដ្ឋកម្ម ទាំងក្បាលម៉ាស៊ីនដឹកនាំនៃរបបនេះ។

### ២) ជនជាប់ចោទបានដឹងអំពីឧក្រិដ្ឋកម្មដែលគេចោទប្រកាន់លើពួកគាត់ ដោយមូលហេតុពួកគាត់មានមុខងារជាអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យ

៣៣. ជនជាប់ចោទធ្វើបណ្ដឹងឧទ្ធរណ៍ដោយផ្អែកជាពិសេសលើការរំលោភគោលការណ៍នីត្យានុកូលភាព ដែលតាមគោលការណ៍នេះ បទប្បញ្ញត្តិដែលហាមឃាត់ឧក្រិដ្ឋកម្មប្រល័យពូជ

---

[40] *ដីកា*សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក កថាខណ្ឌ ២៨៥ និង ៤០៧។

សាសន៍ ការរំលោភដ៏ធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវតែអាចយល់បាន និងអាចដឹងមុនបាន[41]។ ដោយផ្អែកលើគោលការណ៍នេះ ពួកគាត់មិនត្រឹមតែប្រកាសអះអាងអំពីភាពមិនអាចកាត់ទោសពួកគាត់បាន អំពីបទឧក្រិដ្ឋអន្តរជាតិ ដែលមិនត្រូវបានយកមកអនុវត្តជាថ្មី និងដាក់ទោសតាមច្បាប់ព្រហ្មទណ្ឌជាតិ នៅសម័យអង្គហេតុប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំង អំពីការដែលពួកគាត់មិនដឹងថាអំពើទាំងអស់ត្រូវបានធ្វើឲ្យក្លាយជាបទឧក្រិដ្ឋទៀតផង។

៣៤. ក៏ប៉ុន្តែ ដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេត បានធ្វើការសន្និដ្ឋាន ដោយមានហេតុផលច្បាស់លាស់ ដោយគោរពគោលការណ៍នីត្យានុកូលភាព ក្នុងដីកាដំណោះស្រាយ ក្នុងក្របខណ្ឌនៃការវិភាគអំពី "ច្បាប់ដែលអាចយកមកអនុវត្តបាន" របស់ពួកគាត់។ ពួកគាត់ប្រកាសថា៖ "ម្យ៉ាងទៀត បទប្បញ្ញត្តិនៃច្បាប់អន្តរជាតិបង្ក្រាបឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើអនុសញ្ញា ទីក្រុងហ្សឺណែវនៃឆ្នាំ១៩៤៩ ដែលចែងយ៉ាងច្បាស់លាស់អំពីទំនួលខុសត្រូវព្រហ្មទណ្ឌ ជាការដាក់កំហិតតាមផ្លូវច្បាប់ទៅលើប្រទេសកម្ពុជា [...] អាស្រ័យហេតុនេះ បទប្បញ្ញត្តិទាំងនេះត្រូវតែអាចគេចាត់ទុកថាសមល្មមនឹងអាចយល់បានដោយជនត្រូវចោទ <u>ក្នុងឋានៈជាសមាជិកអាជ្ញាធរដឹកនាំប្រទេសកម្ពុជា។</u> ទាក់ទងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ លក្ខណៈដែលអាចដាក់ទណ្ឌកម្មបានរបស់វា នៅក្នុងច្បាប់ទំនៀមទំលាប់ ត្រូវតែបានគេចាត់ទុកថាធុនល្មមនឹងអាចយល់បានដោយជនត្រូវចោទ <u>ដោយហេតុថាមានការកាត់សេចក្តី បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ ឧទាហរណ៍ដូចជានៅទីក្រុង នូរឹមប៊ែក (Nuremberg) និងទីក្រុងតូក្យូជាដើម</u>"[42]។

---

[41] *បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/2/1 កថាខណ្ឌ ០៧ និងកថាខណ្ឌបន្តបន្ទាប់ ; *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* , ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/3/1 កថាខណ្ឌ ២៤ និងកថាខណ្ឌបន្តបន្ទាប់; *បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/1/6 កថាខណ្ឌ ១០៣ និង និងកថាខណ្ឌបន្តបន្ទាប់។

[42] *ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត* កថាខណ្ឌ ១៣០៥ និង ១៣០៦។ (យើងជាអ្នកគូសពីក្រោម)។

៣៥. ដើមបណ្ដឹងរដ្ឋប្បវេណីចង់បញ្ជាក់ផងដែរថា ក្រោយសង្គ្រាមលោកលើកចុងក្រោយនេះ ជនជាប់ចោទបានរស់នៅប្រទេសបារាំង ដែលនៅទីនោះ បណ្ដាញសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្សេងទៀត មានការចុះផ្សាយពីកិច្ចពិភាក្សារយៈពេលយូរ និងក្បោះក្បាយ អំពីសញ្ញាណស្ដីអំពីអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ដើមបណ្ដឹងរដ្ឋប្បវេណីចង់បញ្ជាក់ទៀតថា ឧទាហរណ៍ នៅឆ្នាំ១៩៦០ កាសែតអុយម៉ានីតេ (Humanité) ដែលជាកាសែតរបស់បក្សកុំមុយនីស្ដបារាំង បានដាក់ចំណងជើង អត្ថបទមួយចុះផ្សាយនៅថ្ងៃទី១១វិច្ឆិកា ថា "ជនជម្លៀសពីរនាក់នៅក្នុងជំរំមរណៈរបស់អាឡឺម៉ង់"[43] ដោយមានអមដោយរូបភាពមួយចំនួន។ ដូចគ្នាផងដែរ ខ្សែភាពយន្តរឿង "Facing Genocide – Khieu Samphan and Pol Pot" របស់លោក David Aronwitsch និងលោក Staffan Lindberg ស្ដែងឲ្យឃើញថា កាលពីឆ្នាំ១៩៧៦ នាទីក្រុងប៉ារីស លោក សឺន សាន អតីតសមាជិករដ្ឋាភិបាលរបស់ព្រះអង្គម្ចាស់សីហនុ បានអំពាវនាវឲ្យលោក ខៀវ សំផន ត្រឡប់មករកផ្លូវត្រូវវិញ ដោយប្រកាសថានយោបាយ ដែលគាត់ប្រកាន់យក មានលក្ខណៈអត្តឃាត និងមិនអាចយល់បាន ដោយសារវាចេញអំពីសំណាក់អ្នកស្នេហាជាតិខ្មែរ[44]។ ជនជាប់ចោទសុទ្ធតែជាសមាជិកបក្សកុំមុយនីស្ដ ហើយបានតាមដានសារព័ត៌មាន ដោយចំណាប់អារម្មណ៍ខ្លាំង ហើយដូចដែលសហចៅក្រម ស៊ើបអង្កេតបានគូសបញ្ជាក់ ពួកគាត់តាមដានមើលសារព័ត៌មានអន្តរជាតិទាំងអស់ និងពាក្យសម្ដី ទាំង

[43] អត្ថបទមានចំណងជើងថា « ជនជម្លៀសពីរនាក់ នៅជំរំមរណៈអាល្លឺម៉ង់ » ផ្សាយក្នុងសារព័ត៌មាន Journal L'Humanité ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៦០។

[44] ខ្សែភាពយន្តរឿង Facing Genocide "ខៀវ សំផន និងប៉ុល ពត" របស់លោក David Aronowitsch និងលោក Staffan Lindberg ចេញបញ្ចាំងនៅឆ្នាំ២០១០ ពីនាទីទី២៥:៤០ ដល់នាទីទី២៦:៥៣ ៖ "អ្វីដែលពួកគាត់កំពុងធ្វើបច្ចុប្បន្ននេះ មិនអាចអភិវឌ្ឍប្រទេសកម្ពុជាបានទេ។ វាមិនអាចនាំប្រទេសកម្ពុជាទៅកាន់ឯករាជ្យភាពបានឡើយនៅថ្ងៃអនាគត។ ខ្ញុំអាចយល់នយោបាយនេះបាន តែក្នុងករណីដែលអ្នកអនុវត្តវាជាសត្រូវរបស់ប្រទេសកម្ពុជាតែមួយគត់។ ប៉ុន្តែ អ្នកស្នេហាជាតិ អ្នកស្នេហាជាតិដ៏ពិតៗ ដូចជាលោកខៀវ សំផន ដូចដែលខ្ញុំធ្លាប់ស្គាល់ ហើយដែលខ្ញុំសន្មតថាគាត់នៅតែជាអ្នកស្នេហាជាតិរហូត អ្នកស្នេហាជាតិដ៏ល្បីល្បាញ ខ្ញុំគិតថាវាជានយោបាយអត្តឃាត។ ដូច្នេះ ខ្ញុំសុំឲ្យគាត់ ខ្ញុំអំពាវនាវម្ដងទៀត ក្នុងឋានៈជារៀមច្បង (ខ្ញុំស្គាល់គាត់ច្បាស់ ហើយខ្ញុំស្រលាញ់ចូលចិត្តគាត់) សូមឲ្យគាត់សម្លឹងមើលអនាគតកាល។ អ្វីដែលគាត់កំពុងធ្វើបច្ចុប្បន្ននេះ គឺជាការនាំយកប្រទេសកម្ពុជាទៅកាន់ការសម្លាប់ខ្លួនឯង"។

ឡាយរបស់ជនជាតិខ្មែររស់នៅបរទេសយ៉ាងជិតដល់[45]។ ម៉្យាងទៀត ពួកជនជាប់ចោទទាំងនេះបានកាន់តំណែង នៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលអាចឲ្យពួកអាចដឹងអំពីព័ត៌មានដ៏ស៊ីជម្រៅស្តីអំពីច្បាប់ជាធរមាន និងអនុសញ្ញាដែលអាចអនុវត្តបាន ក្នុងកម្រិតអន្តរជាតិ។ ការដឹងឮនេះកាន់តែច្បាស់ទៅទៀត ដោយមូលហេតុថា នៅឆ្នាំ១៩៧៨ សមាជិកនៃកម្ពុជាប្រជាធិបតេយ្យពុំបានរារែក ក្នុងការសុំអន្តរាគមនៅមហាសន្និបាតអង្គការសហប្រជាជាតិ ដើម្បីឲ្យថ្កោលទោសការឈ្លានពានដែលត្រូវបានអះអាងថាមាន និងការរំលោភបំពានផ្នែកយោធាអំពី សំណាក់ប្រទេសវៀតណាម[46]។

៣៦. ជនជាប់ចោទទាំងបី លោក នួន ជា លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ សុទ្ធតែជាសមាជិកនៃ "អាជ្ញាធរដឹកនាំរបស់កម្ពុជា" ជាពិសេសក្នុងឋានៈតាម លំដាប់លំដោយ ជាសមាជិកពេញសិទ្ធិ នៃគណៈកម្មាធិការមជ្ឈិម (និងជាពិសេស ជាអនុលេខានៃគណៈកម្មាធិការមជ្ឈិម យ៉ាងហោចណាស់ ក៏ចាប់ពីការប្រកាស ជាសាធារណៈ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៧)[47] សមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និងអចិន្ត្រៃយ៍ និងឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងកិច្ចការ បរទេស[48] ព្រមទាំងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច[49]។

៣៧. ដូច្នេះ ផ្ទុយស្រលះពីអ្វីដែលលោកស្រី អៀង ធីរិទ្ធ បានលើកឡើងថា ៖ "សហចៅក្រមស៊ើបអង្កេតខកខានមិនបានបែងចែកឲ្យដាច់ស្រឡះជាមូលដ្ឋាន រវាងបទប្បញ្ញត្តិអន្តរជាតិ "ដែលទប់ស្កាត់"អំពើប្រល័យពូជសាសន៍ ដែលចងកាតព្វកិច្ចចំពោះរដ្ឋភាគី និងបទប្បញ្ញត្តិច្បាប់អន្តរជាតិ "ដែលចែងជាបទល្មើសព្រហ្មទណ្ឌ" ចំពោះបទឧក្រិដ្ឋបែបនេះ ដែលចង

---

[45] *ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427 កថាខណ្ឌ ៨៦។

[46] *សុន្ទរកថារបស់ អៀង សារី* មហាសន្និបាតលើកទី៣៣ សម័យប្រជុំពេញអង្គ ឯកសារ D313/1.2.378 កថាខណ្ឌ ៩០ និងកថាខណ្ឌបន្តបន្ទាប់។

[47] *ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត* កថាខណ្ឌ ៨៦៩ និងកថាខណ្ឌបន្តបន្ទាប់ ស្តីពីតួនាទី និងមុខងាររបស់ នួន ជា។

[48] *ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត* កថាខណ្ឌ ១០០១ និងកថាខណ្ឌបន្តបន្ទាប់ ស្តីពីតួនាទីនិងមុខងាររបស់ អៀង សារី។

[49] *ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត* កថាខណ្ឌ ១២០៧ និងកថាខណ្ឌបន្តបន្ទាប់ ស្តីពីតួនាទីនិងមុខងាររបស់ អៀង ធីរិទ្ធ។

កាតព្វកិច្ចចំពោះប្រជាពលរដ្ឋរបស់រដ្ឋជាគូភាគី[50]"។ លោកស្រី អៀង ធីរិទ្ធ មិនមែនជាប្រជាពលរដ្ឋ "សាមញ្ញ"ធម្មតាទេ។ គាត់មានឋានៈខ្ពស់នៅក្នុងសង្គម និងស្ថិតក្នុងវង្សត្រកូលអ្នកចេះដឹងខ្ពស់។ អាស្រ័យហេតុដូច្នេះ គាត់បានទទួលការអប់រំ នៅប្រទេសកម្ពុជា និងប្រទេសបារាំង ដែលធ្វើឱ្យគាត់អាចពិគ្រោះព័ត៌មានជាច្រើនទាក់ទង ជាពិសេស ជាមួយនឹងការជំនុំជម្រះសេចក្ដីជាអន្តរជាតិល្បីៗជាងគេ នៅទីក្រុង នូរ៉ឹមប៊ែក និងទីក្រុងតូក្យូ ក៏ លើសពីនេះទៀត ជាមួយនឹងការផ្ដល់សច្ចាប័នលើអនុសញ្ញាទីក្រុងហ្សឺណែវ និងអនុសញ្ញាស្ដីអំពីអំពើប្រល័យពូជសាសន៍។ គាត់ពុំអាចមិនបានដឹងអំពី ការផ្ដន្ទាទោសជាឯកឆន្ទនៃឧក្រិដ្ឋកម្ម ដ៏ឃោរឃៅ ដែលត្រូវបានប្រព្រឹត្ត នៅក្នុងអំឡុងសង្គ្រាមលោកលើកទីពីរ និងធ្វើជាមិនដឹងអំពីប្រតិកម្មសង្គម និងតុលាការដែលកើតចេញពីឧក្រិដ្ឋកម្មទាំងនេះបានឡើយ។

៣៨. រឿងនេះក៏ដូចគ្នាសម្រាប់ជនជាប់ចោទទាំងបីនាក់ដែរ។ ឋានៈនិងតួនាទីរបស់ពួកគាត់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ជាភស្តុតាងស្រាប់។

៣៩. ការតស៊ូប្រឆាំងនឹងនិទណ្ឌភាពពុំមានទាំងព្រំដែនកាល ទាំងព្រំដែនអាកាស។

## សេចក្ដីសន្និដ្ឋាន

៤០. ជាការសន្និដ្ឋាន អនុលោមតាមលក្ខខណ្ឌចែងដោយសាលាឧទ្ធរណ៍នៃតុលាព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី[51] ដែលយកមកអនុវត្តដោយអង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក ក្នុងសេចក្ដីសម្រេចទាក់ទងនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅ

[50] *បណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី អ្នកស្រី អៀង ធិរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៨ តុលា ឆ្នាំ២០១០ ឯកសារ D427/2/1 កថាខណ្ឌ ៣៦។

[51] រឿងក្ដី *Ojdanic* សាលដីកាលើអញ្ញត្រកម្មនៃអសមត្ថកិច្ច លើកឡើងដោយ Dragoljub Ojdanic - សហឧក្រិដ្ឋកម្មរួម តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ២១។

ក្រុមស៊ើបអង្កេត ស្តីអំពីសហឧក្រិដ្ឋកម្មរួម[52] និងដោយយោងទៅលើទឡ្ហីករណ៍លំអិតខាងលើ វាស្តែងឲ្យឃើញថា ឧក្រិដ្ឋកម្មអន្តរជាតិស្ថិតនៅក្រោមយុត្តាធិការ របស់ អ.វ.ត.ក ជាពិសេសដោយមូលហេតុដូចតទៅនេះ៖

- ជនជាប់ចោទម្នាក់ៗសុទ្ធតែអាចដឹងថាថ្ងៃណាមួយ ខ្លួននឹងអាចត្រូវគេចាប់ឲ្យទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ប្រសិនបើខ្លួនធ្លាក់ខ្លួនឲ្យគេចាប់បាន
- រាល់បទឧក្រិដ្ឋសុទ្ធតែត្រូវបានចែង ក្នុងច្បាប់អនុសញ្ញាអន្តរជាតិ និង/ឬច្បាប់ទំនៀមទម្លាប់ នៅសម័យនៃអង្គហេតុ
- នៅសម័យនៃអង្គហេតុ បទប្បញ្ញត្តិច្បាប់ដែលចែងអំពីបទឧក្រិដ្ឋទាំងនេះសុទ្ធតែល្មមនឹងអាចយល់បានដោយជនជាប់ចោទ
- បទឧក្រិដ្ឋនីមួយៗសុទ្ធតែត្រូវបានចែងឡើងយ៉ាងច្បាស់លាស់ ក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

## អាស្រ័យហេតុដូច្នេះ

សូមអង្គបុរេជំនុំជម្រះមេត្តា៖

៤១. ប្រកាសថា ដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន និងត្រឹមត្រូវ តាមទម្រង់ និងគតិច្បាប់។

៤២. កត់សំគាល់ថា ជនជាប់ចោទសុទ្ធតែបានដឹងអំពីភាពព្រៃផ្សៃនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្ត។

៤៣. កត់សំគាល់ថា ជនជាប់ចោទទាំងអស់សុទ្ធតែមានសមត្ថភាពអាចដឹងថា ខ្លួនអាចនឹងត្រូវគេចាប់ឲ្យទទួលខុសត្រូវ។

៤៤. កត់សំគាល់ថា នៅសម័យនោះ ជនជាប់ចោទដឹងអំពីបទបញ្ញត្តិច្បាប់ជាតិ និងអន្តរជាតិ។

---

[52] *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE)* អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/14/15 កថាខណ្ឌ ៤៣។

៤៥. កត់សំគាល់ថា រាល់បទឧក្រិដ្ឋទាំងអស់សុទ្ធតែត្រូវបានចែង ក្នុងច្បាប់អនុសញ្ញាអន្តរជាតិ និង/ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅសម័យនៃអង្គហេតុ។

៤៦. អាស្រ័យហេតុដូច្នេះ ច្រានចោលនូវរាល់សំណើរបស់ជនជាប់ចោទ។

លេខ/No: D427/1/19

# សូមរក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

| | | | |
|---|---|---|---|
| ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១០ | មេធាវី ឡោ ជុនធី<br>មេធាវី Olivier BAHOUGNE | ភ្នំពេញ | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |